សំរេច

មាត្រា ១._ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤០០ លានរៀល (បួនរយលានរៀល) ពីជំពូក ៩១ (ចំណាយមិនបានគ្រោងទុក) នៃខវ៉ចំណាយមិនទាន់បែងចែកមកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌) របស់ព្រឹទ្ធសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ។

មាត្រា ២._ ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ ជួយជនរងគ្រោះដោយទឹកជំនន់ ។

មាត្រា ៣._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្តេចប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា និងត្រាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៧៧ អនក្រ.បក

## ស្តីពី ការកែសំរួលអនុក្រឹត្យលេខ ៥៤ អនក្រ.បក

## ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ១៩៩៩

## ស្តីពីការកែសំរួលការរៀបចំ និង ការប្រព្រឹត្តទៅរបស់

## គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

www.pheakdeylaw.com

- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១.-** ត្រូវបានកែសំរួលមាត្រា ១ នៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- សម្តេចនាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី១ |
| ៣- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩- តំណាងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១០- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |

ក្នុងករណីក្រសួងមានសហរដ្ឋមន្ត្រីដឹកនាំ សហរដ្ឋមន្ត្រីនោះត្រូវធ្វើជាអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា ២.-** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការ

www.pheakdeylaw.com

អន្តរជាតិ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានភារកិច្ចអនុវត្ត អនុក្រឹត្យនេះឲ្យបានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខា និងត្រានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៧៨ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

www.pheakdeylaw.com